long beach unified school district

# ដំណឹងថ្មីៗពីការលូតលាស់

## ការចូលរួម ▫ លទ្ធផល ▫ សុខុមាលភាព

ខែមករា ២០១៥

## ស្ទង់វាស់និងផ្តល់ដំណឹងពីការលូតលាស់របស់សិស្ស

ឆ្នាំ២០១៥ នឹងមានការពិភាក្សាជាច្រើនអំពី“ទំនួលខុសត្រូវ”-របៀបដែលយើងស្ទង់វាស់និងផ្តល់ដំណឹងពីការលូតលាស់របស់សិស្ស។ តើតែសអ្វីខ្លះដែលសិស្សនឹងត្រូវដាក់ឲ្យធ្វើ? តើការស្ទង់មតិណាខ្លះដែលមាតាបិតាសិស្សនិងបុគ្គលិកយើងត្រូវបំពេញ? តើយើងដឹងពីគុណភាពរបស់សាលារៀនយើងដោយរបៀបណា? ថ្វីបើយើងធ្លាប់ឮសំណួរទាំងនេះរួមមកហើយក្តី ចម្លើយរបស់វាមានភាពស្មុគស្មាញ ដូច្នេះយើងសូមផ្តល់ការពន្យល់ងាយៗដែលអាចជួយអ្នករាល់គ្នាឲ្យយល់អំពីអ្វីៗដែលកំពុងកើតមានឡើង។

ជាសង្ខេប គំរូទំនួលខុសត្រូវរបស់យើងគឺគួចសំដៅទៅលើ ការចូលរួម លទ្ធផល និងសុខុមាលភាពរបស់សិស្សយើង។ ចាប់ផ្តើមនៅខែកុម្ភៈ យើងនឹងពិភាក្សាអំពីប្រធានបទសំខាន់ពីរមុខទៀត: ការស្ទង់ប្រមាណ Smarter Balance Assessment និងការស្ទង់មតិអំពីស្តង់ដាសាមញ្ញនៃមុខវិជ្ជាស្នូល CORE ។

## ការស្ទង់ប្រមាណចំណេះតាមប្រព័ន្ធ Smarter Balance Assessment

ចាប់ផ្តើមជាមួយនឹងការសាកល្បងមើលនៅក្នុងឆ្នាំ២០១៤ សិស្សនៅក្នុងក្រសួងអប់រំឡុងប៊ីចពីថ្នាក់ទី៣ដល់ទី១១ ចាប់ផ្តើមនីតិវិធីនៃ“ការស្ទង់ប្រមាណលទ្ធផលបញ្ចប់” ដែលបានបង្កើតឡើងដោយកម្មវិធីវាយតម្លៃ Smarter Balance Assessment Consortium (SBAC) ។

ការស្ទង់ប្រមាណលទ្ធផលបញ្ចប់ស្ទង់វាស់មើលជំនាញថៃមៗលើគ្នានិងចំណេះចេះដឹងនៅចុងរយៈកាលកំណត់នៃការបង្ហាត់បង្រៀន ដូចជាវគ្គឬថ្នាក់ជាដើម។ ការស្ទង់ប្រមាណតាមអ៊ិនធើនែតនេះគឺស្របតាមតម្រូវការពីរដ្ឋក្នុងការស្ទង់ប្រមាណចំណេះសិស្ស។ SBAC ដែលត្រូវបានហៅជាសាមញ្ញ ត្រូវបានប្រើដោយរដ្ឋមួយចំនួន ហើយគឺជាការស្ទង់ប្រមាណចំណេះតាមរយៈអ៊ិនធើនែត ដែលជួយគ្រូបង្រៀន អភិបាល និងមាតាបិតាឲ្យដឹងអំពីស្នាដៃរបស់សិស្សឆ្ពោះទៅនឹងស្តង់ដាសាមញ្ញនៃមុខវិជ្ជាស្នូល (CCSS) ។ ដោយសារតែការស្ទង់ប្រមាណដូចគ្នាត្រូវបានប្រើប្រាស់ដោយរដ្ឋជាច្រើន យើងមានឱកាសច្រើនជាងមុនក្នុងការវាស់មើលស្នាដៃរបស់សិស្សពីរយៈទស្សនវិស័យទូទាំងប្រទេស។ ផលប្រយោជន៍មួយថែមទៀតដែលសិស្សធ្វើការស្ទង់ប្រមាណចំណេះតាមរយៈអ៊ិនធើនែតគឺថាលទ្ធផលនឹងបានមកវិញឆាប់ជាងកាលពីឆ្នាំមុនៗ ហើយគ្រូបង្រៀននិងមាតាបិតាក៏នឹងបានទទួលលទ្ធផលនោះឆាប់ជាងមុនដែរ ដូច្នេះពួកគាត់អាចជួយសិស្សឲ្យរៀបបំរុងតទៅមុខទៀតក្នុងការរៀនសូត្រ។

CCSS មិនមែនជាកិច្ចការងាយទេ។ ស្តង់ដាទាំងនេះដាក់គោលដៅខ្ពស់សម្រាប់ស្នាដៃសិស្សដើម្បីឲ្យសិស្សទាំងអស់នឹងបានរៀបចំខ្លួនជាស្រេច សម្រាប់ជោគជ័យនៅមហាវិទ្យាល័យនិងអាជីពនៅពេលពួកគេរៀនចប់ពីសាលាវិទ្យាល័យនៅឡុងប៊ីច។ គ្រូបង្រៀនរបស់យើងនិងអភិបាលសាលា កំពុងបានធ្វើកិច្ចការយ៉ាងមមាញឹកដើម្បីបញ្ជាក់ថាថ្នាក់រៀនទាំងអស់ឆ្លងកាត់ទៅស្តង់ដាថ្មី។ ខណៈដែលយើងរំពឹងថាសិស្សយើងនឹងបោះជំហានឆ្ពោះទៅកាន់ស្តង់ដាថ្មីនេះបានយ៉ាងឆាប់ដែលអាចធ្វើទៅបាន យើងក៏ដឹងហើយរំពឹងដែរថា នៅមួយឆ្នាំពីរដំបូង លទ្ធផលនៃការស្ទង់ប្រមាណអាចផ្តល់សុង្កេដ្ឋានថាស្នាដៃមានការចុះអន់ថយជាងមុន។ សូមចងចាំថា ស្តង់ដាថ្មីដែលពិបាកជាងមុនស្របគ្នាជាមួយប្រព័ន្ធស្ទង់ប្រមាណថ្មីផងនោះ វាគឺជាកំណែធ្វើឲ្យក្រិតតាមខ្នាតឡើងវិញទាំងមូល។ នេះគឺមានន័យថា នៅក្នុងមួយឬពីរឆ្នាំដំបូង លទ្ធផលតែស នឹងគ្រាន់តែយកមកប្រើជាខ្សែបន្ទាត់ថ្មីមួយនៃទិន្នន័យ។

ពីការស្ទង់ប្រមាណល្បងមើលដែលដាក់ឲ្យសិស្សជាង៣លាននាក់ធ្វើកាលពីដើមឆ្នាំ២០១៤ ទិន្នន័យខាងក្រោមនេះបង្ហាញពីចំណុចដូចតទៅ:

| | តែស CST 2013 កំរិតចេះគ្រប់គ្រាន់និងខ្ពស់ (រដ្ឋកាលីហ្វ័រនីញ៉ា) | | តែសល្បង SBAC 2014 កំរិតទី៣និងទី៤ (រួមបញ្ចូលរដ្ឋទាំងអស់ដែលចូលរួមក្នុងតែសល្បង) | |
|---|---|---|---|---|
| | អង់គ្លេស | គណិតសាស្ត្រ | អង់គ្លេស | គណិតសាស្ត្រ |
| ថ្នាក់ទី៤ | 65% | 72% | 41% | 37% |
| ថ្នាក់ទី៦ | 60% | 55% | 41% | 33% |

*យើងសូមលើកទឹកចិត្តលោកអ្នកឲ្យគាំទ្រកូនដោយពិភាក្សាអំពីលទ្ធផលតែសរបស់គេនៅខាងមុខក្នុងឆ្នាំនេះ ប៉ុន្តែសូមកុំមានការបារម្ភពី ប្រសិនបើលោកអ្នកឃើញថាមានការចុះអន់ថយលើលទ្ធផលតែសដំបូងរបស់កូន។ ខណៈដែលយើងបានដាក់គោលដៅខ្ពស់ វាត្រូវការពេលវេលាខ្លះទម្រាំនឹងគ្រូបង្រៀនព្រមទាំងការរៀនសូត្រសម្របខ្លួនទៅតាមគោលដៅនោះ។*

## តើមានអ្វីខ្លះដែលយើងកំពុងធ្វើដើម្បីជួយសិស្សរៀបបំរុងសម្រាប់ការស្ទង់ប្រមាណថ្មី (SBAC) នេះ?

* គ្រប់សាលារៀនយើងទាំងអស់មានយ៉ាងតិចថ្នាក់កុំព្យូទ័រមួយ (សាលាខ្លះមានដល់ទៅ៣) ដែលសិស្សនឹងធ្វើតែសតាមរយៈអ៊ិនធើនែត។ គ្រូបង្រៀននឹងនាំសិស្សចូលថ្នាក់កុំព្យូទ័រនៅក្នុងខែមករានិងខែកុម្ភៈ ដើម្បីធ្វើតែសហាត់សម ហើយនិងហាត់សមប្រើជំនាញដែលចាំបាច់សំរាប់ឲ្យមានជោគជ័យលើ SBAC។

* មានធនធានបច្ចេកវិទ្យាមួយចំនួនសម្រាប់គ្រូបង្រៀននិងមាតាបិតានៅក្នុងគេហទំព័រ Lbschools.net ។ រកមើលការបង្ហាត់ពីបច្ចេកវិទ្យា Technology Instruction នៅក្នុងបញ្ជីលេខរៀងតួរអក្សរពី A-Z រួចចុចលើពាក្យ Curriculum Documents។

## ការស្ទង់មតិ

ក្រសួងអប់រំឡុងប៊ីចបានទទួលការលើកលែងសារជាថ្មីពីសហព័ន្ធសម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ ដែលអនុញ្ញាតឲ្យក្រសួងអប់រំមានភាពងាយស្រួលក្នុងការប្រើប្រាសប្រាក់យោងតាមសេចក្តីចាំបាច់របស់សិស្ស។ ក្រសួងអប់រំបានបង្វែរថវិកាសហព័ន្ធទៅអន្តរាគមនៅសាលារៀនសម្រាប់សិស្ស។ ជាចំណែកមួយនៃការលើកលែងនេះ (ដែលស្គាល់ថាជាការលើកលែង CORE) និងទំនួលខុសត្រូវដែលទាក់ទងនឹងការលើកលែងនេះ សិស្សជាច្រើនបុគ្គលិកសាលា និងមាតាបិតានឹងចូលរួមធ្វើការស្ទង់មតិនៅអនាគតខ្លីខាងមុខនេះ។ ការស្ទង់មតិនៅឆ្នាំនេះនឹងត្រូវចាត់ទុកថាជាតែសល្បងមើល។ នេះគឺមានន័យថាលទ្ធផលនឹងផ្តល់ជាព័ត៌មានយ៉ាងធំធេងដល់គ្រូបង្រៀននិងអភិបាលសាលា ដើម្បីធ្វើការពិនិត្យសារឡើងវិញមើល ប៉ុន្តែលទ្ធផលនឹងគ្រាន់តែជាព័ត៌មានខ្សែបន្ទាត់គោលប៉ុណ្ណោះ មិនមែនជាទំនួលខុសត្រូវជាផ្លូវការទេ។

ខុសគ្នាពីតែសដែលសិស្សធ្លាប់ធ្វើជារឿយៗ ការស្ទង់មតិនៅឆ្នាំនេះនឹងទាក់ទងទៅលើៈ

- សិស្សពីថ្នាក់ទី៤ដល់ទី១២ - អារម្មណ៍លើសង្គម សុខុមាលភាព និងបរិយាកាសនិងវប្បធម៌សាលា។
- បុគ្គលិកសាលា(គ្រូបង្រៀននិងបុគ្គលិកសាលា) - បរិយាកាសនិងវប្បធម៌សាលា។
- មាតាបិតា - អារម្មណ៍លើសង្គម សុខុមាលភាពរបស់សិស្ស និងបរិយាកាសនិងវប្បធម៌សាលា។

សំណួរនៃការស្ទង់មតិដែលនឹងប្រើនៅដើមឆ្នាំនេះត្រូវបានសាកល្បងមើលនៅក្រសួងអប់រំផ្សេងទៀតហើយនិងត្រូវបានសិក្សាដោយអ្នកស្រាវជ្រាវ។ សំណួរនឹងទាក់ទងលើគោលប្រធានដែលជួយគ្រូបង្រៀននិងអភិបាលសាលាឲ្យយល់ពីរបៀបដែលសិស្សមានអារម្មណ៍អំពីសាលារៀន តើពួកគេមានភាពស្រួលក្នុងចិត្តដល់កំរិតណានៅក្នុងការការរៀនសូត្រនិងការលូតលាស់ ហើយអំពីរបៀបធ្វើឲ្យប្រសើរឡើងនៅសាលារៀនដើម្បីឲ្យសិស្សរៀនឆាប់ចេះ។ មាតាបិតានិងគ្រូបង្រៀនក៏នឹងត្រូវសួរសំណួរស្រដៀងគ្នានេះដែរ។

### *នៅពេលណាហើយដោយរបៀបណាដែលយើងនឹងធ្វើការស្ទង់មតិ CORE នេះ?*

* លោកអ្នកនឹងបានទទួលព័ត៌មានក្បោះក្បាយថែមទៀតពីសាលារៀនកូនលោកអ្នក តាមរយៈ School Loop និង School Messenger (ទូរស័ព្ទ) អំពីរបៀបបំពេញការស្ទង់ប្រមាណនេះ។ សូមរង់ចាំទទួលដំណឹងជាបន្តបន្ទាប់!

* សិស្សនឹងធ្វើការស្ទង់មតិនៅក្នុងថ្នាក់កុំព្យូទ័រនៅសាលារៀន។

ទាំងតែស SBAC និងទាំងការស្ទង់មតិនេះគឺជាចំណែកមួយនៃផែនការណ៍គ្រប់គ្រងលើទំនួលខុសត្រូវរបស់សាលាដែលគឺជាតម្រូវការមួយដែលភ្ជាប់ជាមួយថវិការបស់រដ្ឋ។ វាក៏ជាផ្នែកមួយដែរនៃការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការអប់រំ ដែលជួយយើងឲ្យប្រព្រឹត្តស្របទៅនឹងតម្រូវការរបស់សហព័ន្ធ ជំនួសច្បាប់ No Child Left Behind ។

សំខាន់ជាងគេបំផុត ទាំងតែស SBAC និងទាំងការស្ទង់មតិនេះឆ្លុះបញ្ចាំងនូវបេសកម្មរបស់យើង គឺ “ដើម្បីគាំទ្រដល់ជោគជ័យផ្ទាល់ខ្លួននិងប្រាជ្ញា របស់សិស្សរាល់គ្នា រាល់ថ្ងៃ”